សលាកប័ត្រព័ត៌មានប្រចាំខែ
KRT WATCH
លេខៈ ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

# ឃ្លាំមើល សាលាក្ដីខ្មែរក្រហម

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CCPCR - CDP - CHHRA - CKIMHRDA - CWCC - GENEROUS - IDA - KKKHRO - KKKHRDA - KID - KSA - KYA - LAC - LICADHO - OUTREACH - TASK FORCE - VIGILANCE

## សេចក្ដីប្រកាសព័ត៌មាន

### គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមអំពាវនាវឱ្យមានការបង្ហាញជាសាធារណៈនូវលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើស និង បញ្ជីឈ្មោះបេក្ខជនជាចៅក្រម និង សហព្រះរាជអាជ្ញាកម្ពុជា សំរាប់តែងតាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ កន្លងទៅ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលរួមមាន អង្គការ-សមាគម ១៨ជាសមាជិក បានចេញសេចក្ដីប្រកាសព័ត៌មាន ដែលមានអត្ថន័យថាៈ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមស្វាគមន៍ចំពោះអង្គការសហប្រជាជាតិ ដែលបានបញ្ចេញជាសាធារណៈនូវបញ្ជីឈ្មោះបេក្ខជន ដែលកំពុងពិចារណាក្នុងការចាត់បញ្ជូនមកឱ្យឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីតែងតាំងជាចៅក្រម និងសហព្រះរាជអាជ្ញាអន្តរជាតិបំរើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

អង្គការសហប្រជាជាតិបានបង្ហាញនូវលក្ខណៈវិនិច្ឆ័យ និងលក្ខណៈសម្បត្តិសំរាប់តែងតាំងនៅពេលដែលខ្លួនបញ្ជូនលិខិតទៅកាន់រដ្ឋជាសមាជិក ក្នុងការចាត់បញ្ជូនបេក្ខជនរបស់ខ្លួន កាលពីថ្ងៃ៣០ ខែមិថុនា ឆ្នាំ២០០៥ ។ ថ្មីៗនេះ អង្គការសហប្រជាជាតិបានបង្ហាញបញ្ជីឈ្មោះបេក្ខជន ដែលកំពុងស្ថិតក្នុងការពិចារណាសំរាប់ចាត់បញ្ជូនមកធ្វើជាចៅក្រម និង សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ហើយការធ្វើដូច្នេះគឺជាការផ្ដល់ឱកាសឱ្យសាធារណជនអាចធ្វើមូលវិចារណ៍លើបេក្ខជននីមួយៗ មុនពេលអង្គការសហប្រជាជាតិធ្វើសេចក្ដីសំរេចចុងក្រោយ ។

ការបង្ហាញលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើស និង បញ្ជីឈ្មោះបេក្ខជនជាសាធារណៈមុនពេលធ្វើការតែងតាំង គឺជាដំណាក់កាលដ៏សំខាន់ ព្រោះជាការជំរុញឱ្យមានការចូលរួម និងមានទំនុកទុកចិត្តពីសាធារណជនមកលើលទ្ធផលរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ លើសនេះទៅទៀត ការបង្ហាញលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើស និង បញ្ជីរឈ្មោះបេក្ខជន នឹងកាត់បន្ថយនូវការរិះគន់ពីសំណាក់សាធារណជនដែលថា ដំណើរការជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញា ស្ថិតក្រោមឥទ្ធិពលនយោបាយ ។ ការតែងតាំងចៅក្រម និងព្រះរាជអាជ្ញា ដោយត្រឹមត្រូវ យុត្តិធម៌ មិនលំអៀង ឯករាជ្យ និងមានសមត្ថភាពឱ្យបំរើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺជាកត្តាដ៏សំខាន់ដើម្បីធានាថាដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញឯករាជ្យ និងមានស្តង់ដារអន្តរជាតិ ។ ដោយផ្អែកលើគោលការណ៍នេះ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ទទូចសុំឱ្យរដ្ឋាភិបាលកម្ពុជាមេត្តា ÷

- បង្ហាញជាសាធារណៈនូវលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសចៅក្រម និង សហព្រះរាជអាជ្ញាកម្ពុជាបំរើការនៅអង្គជំនុំជម្រះវិសាមញ្ញ
- បង្ហាញឈ្មោះ និង ព័ត៌មានឱ្យបានគ្រប់គ្រាន់ពីបេក្ខជននីមួយៗ ដែលកំពុងស្ថិតក្នុងការពិចារណា ដើម្បីឱ្យសាធារណជនអាចធ្វើមូលវិចារណ៍លើបេក្ខជនទាំងនោះ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើស មុនពេលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមធ្វើការតែងតាំង ។
- ត្រូវធានាថា ដំណើរការតែងតាំងមានលក្ខណៈបើកចំហ តម្លាភាព វត្ថុវិស័យ និង ផ្អែកលើលក្ខណៈសម្បត្តិខ្ពស់ សុចរិតថ្លៃថ្នូរ និង មិនលំអៀង ។

លេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្មៈ ផ្ទះលេខ១២ ផ្លូវលេខ២៨២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន។ ទូរស័ព្ទ/ទូរសារៈ (០២៣) ៣៥១ ៤១៥ អ៊ីមែលៈ chrac@forum.org.kh

## ការតែងតាំងមន្ត្រីរដ្ឋបាលជាន់ខ្ពស់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញៈ ប្រធាន និង អនុប្រធាន ការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ

យោងទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (អ.ស.ប) ទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មន្ត្រីរដ្ឋបាលជាន់ខ្ពស់សម្រាប់សាលាជម្រះក្តីមេដឹកនាំខ្មែរក្រហមត្រូវបានតែងតាំងរួចហើយ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៥។

ព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** បានឡាយព្រះរាជក្រឹត្យតែងតាំង ឯកឧត្តម **ស៊ាន វិសុទ្ធ** ជាប្រធានការិយាល័យ នៃអង្គជំនុំជម្រះវិសាមញ្ញ និងលោកស្រី **មីសែល លី** ជាអនុប្រធានការិយាល័យរដ្ឋបាល ជាតំណែងដែលលោកស្រីត្រូវប្រកាសតែងតាំងកាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០០៥ ដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។

ឯកឧត្តម **ស៊ាន វិសុទ្ធ** ធ្លាប់បានបំពេញនូវតំណែងរដ្ឋបាលសំខាន់ៗមួយចំនួនក្នុងរដ្ឋបាលកម្ពុជា (រួមមានៈ ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងការបរទេស និងលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់) ហើយចាប់តាំងពីឆ្នាំ ១៩៩៩ មក ឯកឧត្តមបានបំពេញតួនាទីជាលេខាធិការប្រតិបត្តិរបស់ ក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេស ដើម្បីរៀបចំការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម។ ឯកឧត្តម **ហែម ក្រាញ់ តូនី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ត្រូវបានតែងតាំងជាប្រធានការិយាល័យរដ្ឋបាលបំរុង នៅក្នុងព្រះរាជក្រឹត្យជាមួយគ្នានេះដែរ។

លោកស្រី **មីសែល លី** នឹងដឹកនាំគណៈប្រតិភូអង្គការសហប្រជាជាតិមួយ ដើម្បីធ្វើការវាយតម្លៃអំពីការចាប់ផ្តើមដំណើរការសាលាក្តីនេះ មកកាន់ទីក្រុងភ្នំពេញនៅដើមខែធ្នូខាងមុខនេះ ដើម្បីពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា អំពីចំណុចលំអិតនៃការបង្កើត អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងពេលប៉ុន្មានខែខាងមុខនេះ។

## អង្គការសហប្រជាជាតិត្រៀមរៀបចំបេក្ខជនសម្រាប់តំណែង ចៅក្រមអន្តរជាតិ ប្រចាំអង្គជំនុំជម្រះវិសាមញ្ញ

បណ្តាបេក្ខជនសម្រាប់តំណែង ចៅក្រមអន្តរជាតិ នៅអង្គជំនុំជម្រះវិសាមញ្ញ ឬសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលជាប់ការជ្រើសរើសដំណាក់កាលដំបូង នឹងត្រូវមន្ត្រីអង្គការសហប្រជាជាតិ (អ.ស.ប) ធ្វើការសម្ភាសន៍ នៅដើមខែធ្នូខាងមុខនេះ។

យោងទៅតាមសេចក្តីរាយការណ៍ព័ត៌មានមួយ ដែលបានធ្វើឡើងកាលពីថ្ងៃទី ២៣ ខែវិច្ឆិកា កន្លងទៅ មិនបានបញ្ជាក់ថាមានបេក្ខជនសម្រាប់តំណែងចៅក្រមអន្តរជាតិប៉ុន្មានរូបទេ ដែលបានជាប់ការជ្រើសរើសនៅក្នុងដំណាក់កាលដំបូង ប៉ុន្តែគេបានឱ្យដឹងថាបេក្ខជនទាំងនោះនឹងត្រូវបានគេអញ្ជើញមកធ្វើការសម្ភាសន៍នៅដើមខែក្រោយនេះ។

លោក Stephane Dujarric អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិបានប្រាប់ប្រភពព័ត៌មានបរទេសមួយថា បណ្តាបេក្ខជនសម្រាប់តំណែងចៅក្រមអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់រៀបចំសាលាក្តីនឹងត្រូវធ្វើការសម្ភាសន៍នៅដំណាក់កាលបន្តទៀត។

រហូតមកដល់ពេលនេះ គេនៅមិនទាន់បានកំណត់ពេលវេលាច្បាស់លាស់នៅឡើយ ថាតើសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវគេចាប់ផ្តើមដំណើរការឡើងនៅពេលណាទេ។ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានឈានដល់កិច្ចព្រមព្រៀងលើការបង្កើតសាលាក្តីនេះរួចហើយ ប៉ុន្តែបញ្ហាដែលនៅរាំងស្ទះនៅពេលនេះ គឺ បញ្ហាថវិកាសម្រាប់យកមកដំណើរការសាលាក្តី។

*(ប្រភពៈ កាសែតរស្មីកម្ពុជា លេខ ៣៨៣៧)*

# សំណួរ និងចំលើយអំពីបញ្ហានានាទាក់ទិនអង្គជំនុំជម្រះវិសាមញ្ញ ឬសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម

(តពីលេខមុន)

## តើសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហមជាអ្វី?

អង្គជំនុំជំរះវិសាមញ្ញ ឬ សាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជាអង្គជំនុំជំរះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោល គឺ សាលាដំបូង និងតុលាការកំពូល ដើម្បីជំនុំជំរះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភ យ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញា អន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងពេលពី ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩។

## តើការបង្កើតសាលាក្ដីនេះផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជា?

អស់រយៈពេលជាង ២៦ឆ្នាំ ហើយ ដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំយុត្តិធម៌មួយ ដែលបានមកពីការកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ដូចនេះ ការបង្កើតសាលាក្ដីនេះមានសារៈសំខាន់ណាស់ចំពោះប្រទេស និងប្រជាជនកម្ពុជាដូចជាៈ

- ផ្ដល់យុត្តិធម៌ជូនប្រជាជនកម្ពុជា ទាំងអ្នកដែលបាត់បង់ជីវិត និងអ្នកដែលនៅរស់។ គេសង្ឃឹមថា ការកាត់សេចក្ដីប្រកបដោយយុត្តិធម៌នឹងជួយធ្វើឱ្យអ្នកដែលនៅរស់ពីការសំលាប់រង្គាលបានធូរស្បើយពីរបួសអតីតកាល។
- អប់រំប្រជាពលរដ្ឋកម្ពុជាជំនាន់ក្រោយឱ្យយល់ដឹងពីទំព័រប្រវត្តិសាស្ត្រ នៃរបបកម្ពុជាប្រជាធិបតេយ្យនេះ និងចៀសវាងការប្រព្រឹត្តខុសដូចនេះទៀត។
- ពង្រឹងនីតិរដ្ឋរបស់យើង ព្រមទាំងជាឧទាហរណ៍មួយសំរាប់អ្នកទាំងឡាយណា ដែលមិនគោរពច្បាប់ទាំងនៅកម្ពុជា និងសំរាប់របបឃោរឃៅនៅទូទាំងពិភពលោក។ដូចនេះឧក្រិដ្ឋជននឹងយល់ដឹងថា ពួកគេនឹងត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រសិនបើគេបានប្រព្រឹត្តអំពើនោះ។
- ស្វែងរកការពិតជូនជនរងគ្រោះឱ្យបានដឹងពីមូលហេតុដែលនាំឱ្យមានអំពើឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅនេះ។
- ជាគំរូដល់សាលាក្ដីក្នុងស្រុក ដើម្បីរួមវិភាគទានក្នុងការកែទំរង់ប្រព័ន្ធយុត្តិធម៌ឱ្យបានកាន់តែល្អប្រសើរ និងឱ្យកាន់តែមានទំនុកចិត្តពីប្រជាពលរដ្ឋ និង សហគមន៍អន្តជាតិ។
- ចូលរួមវិភាគទានក្នុងការស្តារសង្គមជាតិឡើងវិញតាមរយៈការបង្កើនការយល់ដឹងពីកាន់តែច្រើនពីសាលាក្ដីនេះទៅដល់ប្រជាពលរដ្ឋ និងប្រែក្លាយពីការឈឺចាប់ទៅជាការផ្សះផ្សារជាតិ សន្តិភាព និងអភិវឌ្ឍន៍ សង្គមកម្ពុជាទាំងមូលនាពេលអនាគត។
- លុបបំបាត់វប្បធម៌និទណ្ឌភាពនៅកម្ពុជា។

## តើការបង្កើតសាលាក្ដីកាត់ក្ដីមេដឹកនាំខ្មែរក្រហមដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមបានចាប់ផ្ដើមតាំងពីពេលណា?

នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជា ដែលកាលនោះដឹកនាំដោយសហនាយករដ្ឋមន្ត្រីសម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និង សម្ដេច **ហ៊ុន សែន** បានចរចាជាមួយអង្គការសហប្រជាជាតិ ដើម្បីរៀបចំបង្កើតសាលាជំរះក្ដីមួយកាត់ទោសមេដឹកនាំខ្មែរក្រហម និង អ្នកទទួលខុសត្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការព្រមព្រៀងចុងក្រោយរវាងភាគីទាំងពីរ គឺការបង្កើតសាលាក្ដីចំរុះជាតិ និងអន្តរជាតិមួយ ដែលហៅថា *"អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា"*។ ដូច្នេះ វាត្រូវការប្រើរយៈពេលយ៉ាងយូរ ដើម្បីសិក្សានូវបញ្ហាលំអិតផ្សេងៗជាច្រើននៃប្រភេទតុលាការថ្មីមួយនេះ។ រហូតមកដល់ឆ្នាំ ១៩៩៩ ទើបរាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងក្រុមការងារមួយ ដើម្បីរៀបចំការកាត់សេចក្ដី និងធ្វើការចរចាជាមួយអង្គការសហប្រជាជាតិ។ នៅឆ្នាំ២០០៣ ភាគីទាំងពីរបានឯកភាពព្រមព្រៀងគ្នាលើការបង្កើតសាលាក្ដីនេះដោយបានប្រើប្រាស់ពេលដ៏យូរ ព្រមទាំងការខ្វែងមតិគ្នា និងយល់ច្រឡំច្រើនលើកច្រើនសា។

## តើជនណាខ្លះនឹងត្រូវនាំយកមកធ្វើការកាត់ទោសនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ?

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញកំណត់ថាការជំនុំជម្រះទោស គឺធ្វើឡើងចំពោះតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលបានរៀបចំផែនការ ឬចេញបទបញ្ជា និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ។ ដូច្នេះ អង្គជំនុំជម្រះនេះ នឹងសំរេចថាតើខ្មែរក្រហមជា *"**មេដឹកនាំជាន់ខ្ពស់**"* ហើយអ្នកណា ដែលជា**អ្នកទទួលខុសត្រូវជាងគេក្នុងបទឧក្រិដ្ឋ** នៅក្នុងរបបនោះ។ម្យ៉ាងទៀត តុលាការនេះនឹងស្វែងរកតែមុខសញ្ញាទាំងនេះ គឺមិនមែនស្វែងរកគ្រប់អតីតសមាជិកខ្មែរក្រហម ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមកាន់អំណាចនោះទេ។

## តើមានបទល្មើសអ្វីខ្លះដែលនឹងត្រូវចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះនេះ?

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញសំរាប់កាត់ទោស

មេដឹកនាំខ្មែរក្រហមចែងពីបទឧក្រិដ្ឋដែលនឹងត្រូវធ្វើការចោទប្រកាន់រួមមានដូចជាៈ *បទឧក្រិដ្ឋ ក្នុងស្រុក និង បទឧក្រិដ្ឋអន្តរជាតិ*។ ករណីបទឧក្រិដ្ឋក្នុងស្រុក គឺជាបទឧក្រិដ្ឋទាំងឡាយណាដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដូចជា ៖ មនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា។ ចំណែកឯបទឧក្រិដ្ឋអន្តរជាតិរួមមានដូចជាៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ បទល្មើសបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌និងបទឧក្រិដ្ឋប្រឆាំងទៅលើអ្នកដែលទទួលបានការពារជាអន្តរជាតិដោយយោងតាមអនុសញ្ញាទីក្រុងវីយ៉ែន ឆ្នាំ ១៩៦១។

## តើជនសង្ស័យនឹងទទួលនូវការដាក់ទោសយ៉ាងដូចម្ដេចប្រសិនបើគេត្រូវបានកាត់សេចក្ដីថាមានទោសនោះ?

យោងទៅតាមច្បាប់ស្ដីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញ ការដាក់ទោសអតិបរមា គឺ ទោសមួយជីវិត ចំណែកការដាក់ទោសជាអប្បរមា គឺដាក់គុករយៈពេល៥ឆ្នាំ។ នៅក្នុងច្បាប់នេះមិនចែងពីការកាត់ទោសប្រហារជីវិតទេ ពីព្រោះការកាត់ទោសប្រហារជីវិត គឺខុសនឹងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ តុលាការអាចបញ្ជាឱ្យធ្វើការរឹបអូសទ្រព្យសម្បត្តិ ឬ ថវិកា ដែលជនជាប់ចោទទទួលបានមិនស្របច្បាប់ ឬ ដោយការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ហើយទ្រព្យសម្បត្តិដែលបានរឹបអូសនេះនឹងត្រូវប្រគល់ជូនទៅរដ្ឋ។

## តើមានការលើកលែងទោស ឬមានការអនុគ្រោះទោសចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញដែរឬទេ?

នៅក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និង កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាកំណត់ថារាជរដ្ឋាភិបាលកម្ពុជា បានប្រកាសរួចជាស្រេចហើយនឹងមិនស្នើសុំការលើកលែងទោស ឬការអនុគ្រោះទោសសំរាប់ជនណាម្នាក់ដែលត្រូវធ្វើការស៊ើបអង្កេត ឬត្រូវបានកាត់សេចក្ដីថាមានទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញឡើយ។ ដូច្នេះ នឹងមិនមានការសុំលើកលែងទោស ឬអនុគ្រោះទោសចំពោះជនណាមួយដែលត្រូវបានតុលាការសំរេចថាមានទោសនោះឡើយ។

## តើហេតុអ្វីបានជាតុលាការប្រភេទនេះត្រូវបានយកមកប្រើសំរាប់អង្គជំនុំជម្រះវិសាមញ្ញ?

គំរូតុលាការក្ដីចំរុះនេះត្រូវបានគេមើលឃើញថា ជាមធ្យោបាយមួយដើម្បីផ្ដល់ឱកាសឱ្យមានការចូលរួម និងការពាក់ព័ន្ធយ៉ាងពេញទំហឹងពីសំណាក់ប្រជាជន និងមន្ត្រីកម្ពុជាទូទាំងប្រទេសនៅក្នុងដំណើរការកាត់សេចក្ដីនេះ ហើយទន្ទឹមនឹងនោះធានាឱ្យបាននូវស្តង់ដារអន្តរជាតិ និងការចូលរួមពីសហគមន៍អន្តរជាតិ។ សាលាក្ដីនេះនឹងមិនប្រព្រឹត្តទៅនៅទីក្រុងឡាអេ ទ្វីបអឺរ៉ុប ដែលស្ថិតនៅឆ្ងាយពីប្រទេសយើងនោះទេគឺសាលាក្ដីនេះនឹងប្រព្រឹត្តទៅនៅកម្ពុជា ហើយដំណើរការកាត់សេចក្ដីនឹងត្រូវធ្វើឡើងភាគច្រើនជាភាសាខ្មែរនិងបើកចំហឱ្យមានការចូលរួមពីប្រជាជនកម្ពុជា និងត្រូវរាយការណ៍តាមបណ្ដាញវិទ្យុ ទូរទស្សន៍ និង សារពត៌មានក្នុងស្រុក។

## តើត្រូវចំណាយថវិកាប៉ុន្មានសំរាប់ដំណើរការកាត់ក្ដីនេះ?

ថវិកាសំរាប់ចំណាយក្នុងការកាត់ក្ដីនេះ ត្រូវបានគេប៉ាន់ប្រមាណថា អស់ជាង ៦០ លានដុល្លារអាមេរិកក្នុងរយៈពេល៣ឆ្នាំ គឺប្រមាណជា ២០ លានដុល្លារអាមេរិក ក្នុង ១ឆ្នាំ។ ប៉ុន្តែគំរោងថវិកានេះពុំទាន់បានពិភាក្សាគ្មាចប់សព្វគ្រប់នៅឡើយទេ។ តួលេខថវិកានេះមើលទៅដូចជាច្រើនណាស់ ប៉ុន្តែបើធ្វើការប្រៀបធៀបទៅនឹងការចំណាយរបស់សាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និង សាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា (សាលាក្ដីនីមួយៗចំណាយអស់លើសពី១០០លានដុល្លារអាមេរិកក្នុង១ឆ្នាំៗ) និងនៅតុលាការពិសេសសំរាប់ ប្រទេសសេរ៉ាលីអូន (ការចំណាយអស់ជាង ២៤លានដុល្លារអាមេរិកក្នុង ១ឆ្នាំៗ) ។

## តើតុលាការនេះនឹងត្រូវទទួលថវិកាពីប្រភពណា?

ទាំងរាជរដ្ឋាភិបាលកម្ពុជា និងបណ្ដាប្រទេសមួយចំនួនលើពិភពលោកនឹងចេញសោហ៊ុយចាយវាយសំរាប់ដំណើរការកាត់សេចក្ដីនេះ។ ប្រទេសទាំងឡាយបាននិយាយថា ពួកគេនឹងស្ម័គ្រចិត្តផ្ដល់វិភាគទានហិរញ្ញវត្ថុសំរាប់ការចាយវាយរបស់អង្គការសហប្រជាជាតិ និងជួយរាជរដ្ឋាភិបាល ដើម្បីបង្គ្រប់ការចំណាយរបស់ខ្លួន។ ការផ្ដល់មូលនិធិពិសេសនេះ គឺជាមូលនិធិបន្ថែមដែលមិនប៉ះពាល់ ឬបន្ថយនូវមូលនិធិជំនួយផ្សេងៗទៀត ដែលបានសន្យាផ្ដល់ឱ្យកម្ពុជា ហើយនោះទេ។ គម្រោងថវិកានិងការរៀបចំផ្សេងៗសំរាប់អង្គជំនុំជំរះវិសាមញ្ញនេះកំពុងតែចាត់ចែងឡើងដោយក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសហការជាមួយអង្គការសហប្រជាជាតិសំរាប់ជួយរៀបចំការកាត់ក្ដីខ្មែរក្រហម (UNAKRT) និងបណ្ដាប្រទេស ដែលមានចំណាប់អារម្មណ៍អំពីបញ្ហានេះ។ (<u>ប្រភព</u>: "*ការណែនាំបំភ្លឺអំពីការជំនុំជម្រះមេដឹកនាំខ្មែរក្រហម*" រៀបចំដោយលេខាធិការដ្ឋានរបស់ក្រុមការងាររាជរដ្ឋាភិបាលនៅទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៤)

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ*
*មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អ៊ិន.អ៊ី.ឌី (NED) ទេ ។*

**ឧបត្ថម្ភមូលនិធិដោយៈ អ៊ិន.អ៊ី.ឌី**

NED The National Endowment for Democracy
*Supporting freedom around the world*

*លោកអ្នកអាចស្រាវជ្រាវបន្ថែមនៅលើទំព័រ Website ខាងក្រោម*




**មតិកែលំអ**

លោកអ្នកអាចផ្ដល់មតិកែលំអទាក់ទិននឹងសលាប័ត្រនេះតាមរយៈអាសយដ្ឋានដូចមានខាងក្រោម ។